**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ :...១៣៥...អនក្រ.បក

# អនុក្រឹត្យ

# ស្តីពីការកំណត់ប្រាក់បំណាច់ចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រាក់ឧបត្ថម្ភចំពោះមេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០៣០១ / ០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០៥០៨ / ០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០៥០៨ / ០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ១២០៨ / ១៤២៩ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

- បានឃើញអនុក្រឹត្យ លេខ ១៦ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០២ ស្តីពីមូលនិធិឃុំ សង្កាត់
- បានឃើញអនុក្រឹត្យ លេខ ២៦ អនក្រ.បក ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ឃុំ សង្កាត់
- បានឃើញសេចក្តីណែនាំ លេខ០០៤ សណន ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីបែបបទនីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិ ការតែងតាំងជំនួយការមេភូមិ និងតួនាទីភារកិច្ច របៀបរបបធ្វើការងាររបស់ភូមិ របស់ក្រសួងមហាផ្ទៃ
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១** -

ត្រូវបានកំណត់ប្រាក់បំណាច់ប្រចាំខែចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដូចខាងក្រោម ៖

១- ប្រធានក្រុមប្រឹក្សានិងជាមេឃុំ ចៅសង្កាត់ ក្នុងមួយនាក់ ១៥០ ០០០រៀល ក្នុងមួយខែ(មួយរយហាសិបពាន់រៀលក្នុងមួយខែ)

២- សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដែលទទួលមុខតំណែងជាជំទប់ទី១ និងជំទប់ទី២ ចៅសង្កាត់រងទី១ និងចៅសង្កាត់រងទី២ ក្នុងមួយនាក់ ១២០ ០០០ រៀល ក្នុងមួយខែ ( មួយរយម្ភៃពាន់រៀលក្នុងមួយខែ )

៣- សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលមិនស្ថិតក្នុងមុខតំណែងខាងលើ ក្នុងមួយនាក់ ១០០ ០០០រៀល ក្នុងមួយខែ (មួយរយពាន់រៀលក្នុងមួយខែ ) ។

ត្រូវបានកំណត់ប្រាក់ឧបត្ថម្ភប្រចាំខែចំពោះមន្ត្រីភូមិ ដូចខាងក្រោម ៖

១-មេភូមិក្នុងមួយនាក់ ៦០ ០០០រៀល ក្នុងមួយខែ(ហុកសិបពាន់រៀលក្នុងមួយខែ)

២-អនុប្រធានភូមិក្នុងមួយនាក់ ៥០ ០០០រៀល ក្នុងមួយខែ(ហាសិបពាន់រៀលក្នុងមួយខែ)

៣-សមាជិកភូមិក្នុងមួយនាក់ ៤០ ០០០រៀល ក្នុងមួយខែ(សែសិបពាន់រៀលក្នុងមួយខែ)។

**មាត្រា ២**-

ការផ្តល់ប្រាក់បំណាច់ប្រចាំខែចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រាក់ឧបត្ថម្ភចំពោះមន្ត្រីភូមិ ដូចដែលបានកំណត់ក្នុងមាត្រា១ ខាងលើ ត្រូវអនុវត្តចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងមន្ត្រីភូមិ ដែលស្ថិតក្នុងមុខតំណែងតែប៉ុណ្ណោះ ។ ការផ្តល់ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភនេះ ត្រូវគ្រោងនិងបើកផ្តល់នៅក្នុងថវិកាប្រចាំរបស់ឃុំ សង្កាត់ ដោយគិតចាប់តាំងពីខែមករា ឆ្នាំ២០១១ តទៅ ។

**មាត្រា ៣**-

អនុក្រឹត្យលេខ ៦១ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីការកំណត់ប្រាក់បំណាច់ចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងអនុក្រឹត្យលេខ ១១០ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ

សីហា ឆ្នាំ ២០០៧ ស្ដីពីការកំណត់ប្រាក់ឧបត្ថម្ភចំពោះមេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ២០១០

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីជំរាបជូន
សម្ដេចនាយករដ្ឋមន្ត្រីដើម្បីចុះហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ស ខេង** **គាត ឈន់**

<u>កន្លែងទទួល:</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ដូចចែងក្នុងមាត្រា៤
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ